

# ជំងឺ COVID-19៖ ការពិតនៃថ្នាំបង្ការ
# ការមានកូន និងការមករដូវ

## ជំងឺ COVID-19 និងការមានកូន



- **មិនមានភស្តុតាងណាមួយ** ដែលបញ្ជាក់ថាថ្នាំបង្ការណាក៏ដោយ រួមទាំងថ្នាំបង្ការជំងឺ COVID-19 ទាំងឡាយ បណ្តាលឱ្យមានបញ្ហាមិនមានកូនចំពោះស្ត្រី ឬបុរសនោះទេ។ ការសិក្សានានាបង្ហាញថាមនុស្សដែលបានទទួលចាក់ថ្នាំបង្ការមានអត្រាមានផ្ទៃពោះ ដូចគ្នាទៅនឹងមនុស្សដែលមិនបានចាក់ថ្នាំបង្ការផងដែរ។ មិនមានភស្តុតាងណាមួយដែលបញ្ជាក់ថាថ្នាំបង្ការជំងឺ COVID-19 ទាំងឡាយប៉ះពាល់ដល់ភាពពេញវ័យ ឬការលូតលាស់របស់មនុស្សវ័យជំទង់ឡើយ។
- អ្នកជំនាញផ្នែកសុខភាព **ណែនាំឱ្យទទួលចាក់ថ្នាំបង្ការជំងឺ COVID-19** សម្រាប់អ្នកដែលមានផ្ទៃពោះ ឬអ្នកដែលចង់មានកូននាពេលអនាគត ផងដែរ។




- អ្នកជំនាញទាំងឡាយក៏បានណែនាំផងដែរថា មនុស្សគ្រប់រូប **គួរតែធ្វើឱ្យថ្នាំបង្ការជំងឺ COVID-19 របស់ពួកគេនៅតែ គ្រប់លក្ខណៈនិងទាន់ពេលវេលា។ ចំណុចនេះរួមមានការទទួលចាក់ដូសជំរុញដែលបានធ្វើឱ្យថ្មីឡើងវិញ (បែប ប្រឆាំងនឹងមេរោគពីរប្រភេទ/បាយវ៉ាលិន) (bivalent)** ក្នុងរយៈពេលយ៉ាងហោចណាស់ 2 ខែក្រោយពីការចាក់ដូសលំដាប់ដំបូង ឬក៏ដូសជំរុញចុងក្រោយបង្អស់។ ការធ្វើបែបនេះមានសារៈសំខាន់ជាពិសេសសម្រាប់អ្នកដែលកំពុងព្យាយាមមានផ្ទៃពោះ ឬមានផ្ទៃពោះរួចហើយ។ ជំងឺ COVID-19 អាចមានសភាពកាន់តែមិនល្អ ក្នុងអំឡុងពេលមានផ្ទៃពោះ។ ការឆ្លងជំងឺ COVID-19 ក្នុងពេលមានផ្ទៃពោះ បង្កើនហានិភ័យនៃផលវិបាកសម្រាប់អ្នកមានផ្ទៃពោះ ក៏ដូចជាទារករបស់ពួកគេដែលកំពុងលូតលាស់ផងដែរ។

## ផលប៉ះពាល់បណ្តោះអាសន្ននៃថ្នាំបង្ការ ចំពោះការមករដូវ



- ស្ត្រីមួយចំនួនបានរាយការណ៍អំពីការផ្លាស់ប្តូររដូវរបស់ពួកគេ បន្ទាប់ពីទទួលចាក់ថ្នាំបង្ការជំងឺ COVID-19 រួច។ ការសិក្សាចំនួនពីរនាពេលថ្មីៗនេះបានបង្ហាញថា ជាមធ្យម ពេលវេលាចន្លោះពីវដ្តរដូវមួយទៅវដ្តរដូវមួយទៀតនោះមានការកើនឡើងចំនួនតិចជាងមួយថ្ងៃ នៅក្នុងវដ្តរដូវដែលទទួលចាក់ថ្នាំបង្ការ។ **ការផ្លាស់ប្តូរទាំងនេះគឺបណ្តោះអាសន្នតែប៉ុណ្ណោះ** ហើយមិនមានការផ្លាស់ប្តូរទៅលើចំនួនថ្ងៃដែលមានធ្លាក់ឈាមនោះទេ។
- ចំណុចជាច្រើនអាចបណ្តាលឱ្យមានការផ្លាស់ប្តូរវដ្តរដូវ រួមមានទាំងជំងឺ COVID រយៈពេលវែងផងដែរ។ ការមករដូវមិនទៀងទាត់ គឺជារឿងធម្មតាណាស់ក្នុងចំណោមយុវវ័យ។ ប្រសិនបើអ្នកមានការព្រួយបារម្ភអំពីការមករដូវរបស់អ្នក សូមពិភាក្សាជាមួយនឹងគ្រូពេទ្យ។



សម្រាប់ព័ត៌មានបន្ថែម សូមមើលគេហទំព័រ ថ្នាំបង្ការជំងឺ COVID-19 សម្រាប់មនុស្សដែលចង់មានកូន របស់មជ្ឈមណ្ឌលគ្រប់គ្រងនិងទប់ស្កាត់ជំងឺឆ្លង (CDC)។

### ថ្នាំបង្ការគឺមិនគិតថ្លៃសម្រាប់មនុស្សគ្រប់គ្នា - បើទោះបីជាអ្នកមិនមានធានារ៉ាប់រងក៏ដោយ

អ្នកនឹងមិនត្រូវបានសួរនាំអំពីស្ថានភាពអន្តោប្រវេសន៍របស់អ្នកទេ។ មានទីតាំងចាក់ថ្នាំបង្ការជាច្រើនកន្លែងដែលបើកបម្រើការជូននៅចុងសប្តាហ៍និងពេលល្ងាច ហើយដែលមិនចាំបាច់ធ្វើការណាត់ជួបទេ។ ដើម្បីស្វែងរកទីតាំងមួយដែលនៅជិតអ្នក៖

- សូមចូលទៅកាន់គេហទំព័រ VaccinateLACounty.com ឬទូរស័ព្ទទៅលេខ **1-833-540-0473** ដែលមានបម្រើការជូនចាប់ពីម៉ោង 8:00 ព្រឹក ដល់ម៉ោង 8:30 យប់។
- អ្នកក៏អាចទូរស័ព្ទទៅលេខ 2-1-1 ឬសាកសួរគ្រូពេទ្យ ឬឱសថការី (អ្នកលក់ថ្នាំពេទ្យ) ក្នុងតំបន់របស់អ្នកផងដែរ។
- ការដឹកជញ្ជូនដោយមិនគិតថ្លៃ និងការចាក់ថ្នាំបង្ការនៅតាមផ្ទះក៏មានផ្តល់ជូន ផងដែរ។



County of Los Angeles Public Health
11-4-22 (Cambodian)